សុន្ទរកថារបស់ **ឯកឧត្តម គូម៉ា ម៉ាវ៉ូ យូជិ** ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព

របស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្ដល់ជំនួយឥតសំណង

សម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន

២៥ កុម្ភៈ ២០១៥

- **សូមគោរព លោក កូបាយ៉ាស៊ី ស៊ីហ្គីអូ អនុប្រធានការិយាល័យសមាគមកំចាត់រោគរបេងជប៉ុន នៅកម្ពុជា** (JATA)!
- **សូមគោរព អស់លោក លោកស្រី!**

ថ្ងៃនេះខ្ញុំមា នសេចក្ដីសោមនស្សរីករាយ ដើម្បីប្រារព្ធពិធីចុះហត្ថលេខាផ្ដល់ជំនួយឥតសំណង សម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន ដល់អង្គការJATA សម្រាប់គម្រោងពង្រឹងសមត្ថភាពកំណត់រោគវិនិច្ឆ័យជម្ងឺរបេង នៅស្រុកប្រតិបត្តិពារាំង ខេត្តព្រៃវែង កម្ពុជាដំណាក់កាលទី២ ។

រដ្ឋាភិបាលជប៉ុន បានជួយដល់ការស្ដារ និងអភិវឌ្ឍន៍ប្រទេសកម្ពុជាឡើងវិញនៅលើវិស័យជាច្រើន ចាត់ទុកជាប្រទេសដែលផ្ដល់ជំនួយធំបំផុត។ រដ្ឋាភិបាលជប៉ុន ក៏បានរួមចំណែកក្នុងការធ្វើអោយប្រសើរឡើងនូវវិស័យសុខាភិបាលនៅកម្ពុជាជាច្រើនផងដែរ តាមរយៈការផ្ដល់ជំនួយដើម្បីសាងសង់មន្ទីរពេទ្យនានា រួមទាំងមជ្ឈមណ្ឌលជាតិកំចាត់រោគរបេង និងការបណ្ដុះបណ្ដាលអភិវឌ្ឍន៍ធនធានមនុស្សជាដើម។

តាមរយៈកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា និងប្រទេសផ្ដល់ជំនួយ រួមទាំងប្រទេសជប៉ុនផងដែរនោះ យើងសង្កេតឃើញថា ប៉ុន្មា នឆ្នាំចុងក្រោយនេះ អត្រានៃការឆ្លងរាលដាលនៃជម្ងឺរបេងមានការថយចុះយ៉ាងច្រើនគួរអោយកត់សំគាល់។ ទោះជាយ៉ាងណាក៏ដោយ អត្រានៃការឆ្លងជម្ងឺរបេងនៅកម្ពុជា នៅតែមានកម្រិតខ្ពស់ដែលទាមទារអោយមានការបន្តការខិតខំប្រឹងប្រែងបន្ថែមទៀតដើម្បីកាត់បន្ថយអត្រានៃការឆ្លងជម្ងឺនេះ។

អង្គការJATA បានខិតខំបង្កើនសកម្មភាពរបស់ខ្លួន ដើម្បីទប់ស្កាត់ការឆ្លងជម្ងឺរបេងនៅកម្ពុជាសម្រាប់រយៈពេលដ៏វែងមួយ។ ឆ្នាំមុន នៅក្នុងដំណាក់កាលទី១ អង្គការJATA បានអនុវត្តគម្រោងពង្រឹងសមត្ថភាពការរកឃើញជម្ងឺរបេងក្នុងរយៈពេលយ៉ាងខ្លី តាមរយៈកម្មវិធីបណ្ដុះបណ្ដាលជាច្រើនដល់អ្នកស្ម័គ្រចិត្ត និងបុគ្គលិករបស់មណ្ឌលសុខភាពនានា និងការកំណត់រោគវិនិច្ឆ័យជម្ងឺរបេង តាមរយៈកម្មវិធីបណ្ដុះបណ្ដាលជំនាញផ្សេងៗដល់គ្រូពេទ្យ និងគ្រូពេទ្យផ្នែកវិទ្យុសកម្ម។ នៅក្នុងដំណាក់កាលទី២នេះ អង្គការJATA មានគម្រោងគាំទ្រសកម្មភាពរបស់ខ្លួនជាបន្តទៅទៀតក្នុងតំបន់គោលដៅ ហើយដែលយើងរំពឹងថា នឹងរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រតាមរយៈការកាត់បន្ថយចំនួនអ្នកជម្ងឺរបេងនៅក្នុងតំបន់។

ចុងក្រោយនេះ ជំនួយឥតសំណងសម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន ផ្ដល់ជូនដល់គម្រោងគោលដៅជាច្រើន សម្រាប់អនុវត្តនូវគម្រោងអភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ច និងសង្គមកិច្ចដែលផ្ដល់អត្ថប្រយោជន៍ដល់ប្រជាជននៅកម្រិតមូលដ្ឋាន។ ខ្ញុំសង្ឃឹមថា គម្រោងដែលចុះហត្ថលេខានៅថ្ងៃនេះ នឹងផ្ដល់អត្ថប្រយោជន៍ដោយផ្ទាល់ដល់ប្រជាជននៅក្នុងតំបន់គោលដៅ ព្រមទាំងរួមចំណែកជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាពរវាងជប៉ុន និងកម្ពុជា។

**សូមអរគុណ** !